ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ✓

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## បំភ្លឺករណីនាំចេញខ្សាច់ស៊ីលីកាដែលត្រូវបានចោទប្រកាន់ថាជាការរំលោភលើការផ្អាកបណ្តោះអាសន្ននៃការនាំចេញខ្សាច់

កាលពីល្ងាចថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧ កន្លងទៅនេះ សកម្មជននៃអង្គការមាតាធម្មជាតិ បានបង្ហោះវីដេអូនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនអំពីសកម្មភាពកប៉ាល់ផ្ទុកខ្សាច់នាំចេញទៅក្រៅប្រទេស ក្រសួងរ៉ែនិងថាមពលបានទទួលព័ត៌មាននេះតាមរយៈសំណួរពីបណ្តាសារព័ត៌មាននានា នៅវេលាថ្ងៃត្រង់ ថ្ងៃទី០២ ខែឧសភា ហើយបានធ្វើការស្រាវជ្រាវ និងពិនិត្យឃើញថា៖

- នៅក្នុងវីដេអូឃ្លីបបង្ហោះនៅថ្ងៃទី០១ ខែឧសភា ដោយអង្គការមាតាធម្មជាតិនោះ គ្មានបញ្ជាក់ទីតាំងពិតប្រាកដ ពេលវេលាដែលថត ឈ្មោះកប៉ាល់ និងប្រភេទខ្សាច់នោះឡើយ គ្រាន់តែបញ្ជាក់ថាជាកប៉ាល់យក្សចំណុះ៣០០០០តោន។
- ក្រសួងរ៉ែនិងថាមពលបានចាត់មន្ត្រីមន្ទីរនៃបណ្តាខេត្តជាប់មាត់សមុទ្រទាំងអស់ ត្រួតពិនិត្យមើលថា តើមានកប៉ាល់ណាដែលកំពុងផ្ទុកខ្សាច់ឬទេ ប៉ុន្តែជាលទ្ធផលមន្ត្រីមន្ទីរបានបញ្ជាក់ថាពុំមានកប៉ាល់ចំណុះ៣០០០០តោនឡើយ នៅថ្ងៃទី០២ ខែឧសភានេះ។ ការសួរទៅអង្គការមាតាធម្មជាតិបានបញ្ជាក់ថា វីដេអូនេះបានថតនៅថ្ងៃទី២៩ ខែមេសា នៅចំណុចស្ទឹងហាវ ខេត្តព្រះសីហនុ គឺកប៉ាល់ឈ្មោះ Deryoung SunFlower។
- ព័ត៌មានពីភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" បានបញ្ជាក់ថា កប៉ាល់ដែលចូលមកឈ្មោះ Deryoung SunFlower ដែលមានចំណុះត្រឹមតែ ៨៦៧៩តោន (Gross Tonnage) ប៉ុណ្ណោះ បានចូលមកដែនសមុទ្រកម្ពុជាក្នុងខេត្តព្រះសីហនុ ហើយដែលមានការអនុញ្ញាតពីកាំសាប ដោយភ្ជាប់មកជាមួយនូវប្រតិវេទន៍ចេញ-ចូល ច្បាស់លាស់ត្រឹមត្រូវ គឺចូលមកថ្ងៃទី២៥ ខែមេសា វេលាម៉ោង០៩:០០ ចេញទៅវិញថ្ងៃទី០១ ខែឧសភា វេលាម៉ោង១៥:០០។ ដូច្នេះថ្ងៃដែលអង្គការមាតាធម្មជាតិបង្ហោះវីដេអូនេះគឺថ្ងៃដែលកប៉ាល់បានចាកចេញពីកម្ពុជាទៅហើយ។
- កប៉ាល់ Deryoung Sunflower នេះចូលមកដឹកខ្សាច់ស (ខ្សាច់ស៊ីលីកា) ដែលជាប្រភេទខ្សាច់បម្រើដល់ឧស្សាហកម្មផលិតកញ្ចក់ ដប កែវ ជាដើម។ ការផ្អាកការនាំខ្សាច់ចេញទៅបរទេស

នៅតែជាធរមានដដែល លើកលែងតែខ្សាច់ស៊ីលីកា ដូចដែលបានបញ្ជាក់ក្នុងលិខិតលេខ ២០៧៥ រថ.រស ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងរ៉ែនិងថាមពល។

- ខ្សាច់ស៊ីលីកាដែលបានផ្ទេរពីសាឡង់មកកប៉ាល់ Deryoung Sunflower នោះ មានប្រភពពីទីតាំងអាជីវកម្មរបស់ក្រុមហ៊ុនម៉ុង ឫទ្ធី គ្រុប ខូអិលធីឌី ដែលស្ថិតនៅដែនគោក ក្នុងឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មិនមែនជាខ្សាច់ដែលយកចេញពីព្រែកនានា ដូចដែលសកម្មជនអង្គការមាតាធម្មជាតិចោទប្រកាន់នោះទេ។ ក្រុមហ៊ុននេះបានទទួលគោលការណ៍ធ្វើអាជីវកម្មខ្សាច់ស៊ីលីកា សម្រាប់នាំចេញស្របច្បាប់ពីរាជរដ្ឋាភិបាល និងទទួលបានអាជ្ញាបណ្ណត្រឹមត្រូវ ពីក្រសួងរ៉ែនិងថាមពល។

ក្រសួងរ៉ែនិងថាមពលសូមអំពាវនាវដ៏ទទូចដល់អង្គការមួយចំនួនដែលបានតាំងខ្លួនជានគរបាលមានសមត្ថកិច្ចស៊ើបអង្កេតផង ជាអ្នកសារព័ត៌មានផង និងជាអ្នកជំនាញរ៉ែផង ហើយចោទប្រកាន់ និងវាយតម្លៃដោយគ្មានមូលដ្ឋានទាំងផ្នែកបច្ចេកទេស និងផ្នែកច្បាប់ សូមចូលរួមសហការដោយផ្ទាល់តាមរយៈការផ្តល់នូវរាល់ព័ត៌មានអំពីការសង្ស័យលើភាពមិនប្រក្រតីនានា មកប្រព័ន្ធHotline របស់ក្រសួង លេខ 095727727 ដើម្បីក្រសួងអាចស្រាវជ្រាវ វិនិច្ឆ័យ បំភ្លឺទៅវិញដោយតម្លាភាព ក្នុងករណីគ្មានកំហុសជាក់ស្តែង ឬចាត់វិធានការទាន់ពេលវេលា ក្នុងករណីសកម្មភាពនោះជាបទល្មើសជាក់ស្តែង ចៀសវាងការបង្ហោះព័ត៌មានគ្មានមូលដ្ឋានច្បាស់លាស់តាមទំព័រហ្វេសប៊ុក ដែលនាំឱ្យសាធារណជនមានការភាន់ច្រឡំ។

សូមសាធារណជន ជាពិសេសអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។